# ការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ ចំពោះអំពើជួញដូរមនុស្ស៖ គោលការណ៍ណែនាំអាស៊ាន សំរាប់អ្នកអនុវត្តផ្ទាល់

## ផ្នែកទី១៖ បញ្ហាតស៊ូតាង

### ក.ការពង្រឹងក្របខ័ណ្ឌច្បាប់៖

១-រាល់គ្រប់ទំរង់នៃ អំពើជួញដូរមនុស្ស និង បទល្មើសជួញដូរឆ្លងដែនទាំងឡាយដែលទាក់ទងដាច់ខាត ត្រូវតែចាត់ទុកថាជា បទល្មើសព្រហ្មទណ្ឌ សមស្របនឹងបទដ្ឋានអន្តរជាតិ ដែលអាចអនុវត្តបាន។

២-ទោសបញ្ញត្តិ សំរាប់ជនដែលត្រូវបានកាត់ទោសពីបទល្មើសជួញដូរមនុស្ស និង បទល្មើសដែលទាក់ទង ត្រូវសមាមាត្រទៅនឹង ស្ថានទំងន់នៃបទល្មើស។

៣-បណ្តាបទល្មើសជួញដូរមនុស្ស ព្រមជាមួយ និង បទល្មើសដែលទាក់ទងដល់ អំពើជួញដូរមនុស្ស ត្រូវបានផ្តល់អនុសាសន៏ថា ជាបទល្មើសដែលមានការទាក់ទងនឹងច្បាប់សំអាតប្រាក់។

៤-ដើម្បីធានាមិនឱ្យមាន ជំរកសុវត្ថិភាពសំរាប់ពួកជួញដូរមនុស្ស រដ្ឋនានាត្រូវបានលើកទឹកចិត្តឱ្យធ្វើបត្យាប័នឬផ្តន្ទាទោសជនល្មើសក៏បាន។

៥-បណ្តាសិទ្ធិសញ្ញាបត្យាប័ននិងជំនួយផ្នែកច្បាប់ទៅវិញទៅមកជាទ្វេភាគី និងពហុភាគីដែលមានស្រាប់ និងនៅពេលអនាគត ដែលអាចអនុវត្តបាន ចំពោះអំពើជួញដូរមនុស្ស និងបទល្មើសដែលទាក់ទងនឹង អំពើជួញដូរមនុស្ស។

៦-តាមក៏រិតដែលអាចធ្វើទៅបាន ក្របខ័ណ្ឌច្បាប់ត្រូវផ្តល់លទ្ធភាពដល់ជនរងគ្រោះក្នុងការស្នើសុំ និង ទទួលបានសំណង រួមទាំងសំណងជំងឺចិត្ត ពីប្រភពសមស្របនានាក្នុងនោះរួមមាន ជនទាំងឡាយដែលត្រូវបានកាត់ទោសពីបទជួញដូរមនុស្ស និងបទល្មើសដែលទាក់ទងនានា។

### ខ-ឯកទេសកម្ម និង កិច្ចសហប្រតិបត្តិការ

១-សមត្ថភាពឯកទេសក្នុងការស៊ើបអង្កេត នៅក្នុងក្របខ័ណ្ឌកងកំលាំងនគរបាលជាតិ គឺជាគន្លឹះដ៏សំខាន់ ដល់ការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌបានយ៉ាងខ្លាំងក្លា និង ប្រកបដោយប្រសិទ្ធភាពចំពោះអំពីជួញដូរមនុស្ស។ មន្ត្រីអនុវត្តច្បាប់នៅថ្នាក់មូលដ្ឋានក៏ត្រូវមានការយល់ដឹងអំពីបទល្មើសជួញដូរ និងការទទួលខុសត្រូវរបស់ពួកគេក្នុងការផ្តល់នូវការឆ្លើយតបជាបឋម។

២-បណ្តាស្ថាប័នអយ្យការក៏ត្រូវកសាងសមត្ថភាពជំនាញ ក្នុងការឆ្លើយតបផងដែរដោយត្រូវធ្វើការបណ្តុះបណ្តាលពិសេស និង តែងតាំងព្រះរាជអាជ្ញាមួយចំនួន ដែលមានលក្ខណៈសមស្រប ទៅនឹងចំនួនករណីរឿងក្តីបច្ចុប្បន្ន និងពេលអនាគត ដើម្បីធ្វើការរៀបចំនិងប្រគល់ជូនការចោទប្រកាន់អំពើជួញដូរមនុស្ស និង ករណីរឿងក្តីដែលទាក់ទង។

៣-ត្រូវផ្តល់អាទិភាពដល់ការបង្កើត និង ផ្តល់ការបណ្តុះបណ្តាលជំនាញសំរាប់ ព្រះរាជអាជ្ញា ដែលត្រូវបានតែងតាំង។

៤-ប្រសិនបើចំនួនករណីរឿងក្តីមិនទាន់គំរូវឱ្យមាន ការឆ្លើយតបផ្នែកអយ្យការជំនាញទេនោះ ស្ថាប័នអយ្យការត្រូវតែងតាំងជនបង្គោល សំរាប់ករណីរឿង ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស។

៥-ត្រូវរៀបចំ ជាពិសេស និងតែងតាំងចៅក្រមមួយចំនួន ឱ្យបានសមស្របនឹង ចំនួនករណីរឿងក្តីបច្ចុប្បន្ន និងពេលអនាគត ដើម្បីគ្រប់គ្រង និង វិនិច្ឆ័យលើការជំនុំជំរះ ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស។

៦-ត្រូវធ្វើឱ្យព្រះរាជអាជ្ញានិងចៅក្រមទាំងអស់បានយល់ជ្រួតជ្រាបអំពីបទល្មើសជួញដូរមនុស្សនិងយល់ដឹងអំពីក្របខ័ណ្ឌច្បាប់ ដែលអាចអនុវត្តបាន។

៧-ត្រូវមាន កិច្ចសហប្រតិបត្តិការឱ្យបានជិតស្និទ្ធ រវាងអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញា នៅក្នុងករណីរឿងក្តីជួញដូរ ដោយរួមទាំង ការសហការលើក៏រិតជំនាញ នៅដំណាក់កាលដំបូងៗបង្អស់ ដែលអាចធ្វើទៅបាន ដើម្បីធានាភាពរឹងមាំ ក្នុងការចោទប្រកាន់ករណីរឿងក្តី។

## គ -ការគ្រប់គ្រងជនរងគ្រោះដែលធ្វើជាសាក្សី

១-ព្រះរាជអាជ្ញា និង អ្នកស៊ើបអង្កេត ត្រូវធ្វើការឱ្យបានជិតស្និទ្ធ ដើម្បីធ្វើឱ្យជនរងគ្រោះដោយសារអំពើជួញដូរយល់ព្រមសហការ ធ្វើជាសាក្សី ក្នុងនាមខ្លួនជា ជនរងគ្រោះ ព្រមទាំង ផ្តល់នូវកំណត់ហេតុដែលជាភស្តុតាង ។

២-តាមលទ្ធភាពដែលអាចធ្វើទៅបាន ជនរងគ្រោះដោយសារអំពើជួញដូរ មិនត្រូវធ្វើការចោទប្រកាន់ឬផ្តន្ទាទោស ដោយសារតែពួកគេជាប់ទាក់ទិន ក្នុងការប្រព្រឹត្តបទល្មើស ដោយខ្លួនឯងផ្ទាល់ ដោយសារតែផលវិបាកដោយផ្ទាល់ពីអំពើជួញដូរ ។

៣-ត្រូវផ្តល់ឱ្យជនរងគ្រោះដោយសារអំពើជួញដូរទទួលបានកិច្ចការពារ និង មណ្ឌលស្នាក់នៅ យ៉ាងរួសរាន់ដូចមានចែងដោយច្បាប់ក្នុងស្រុក ។

៤-ត្រូវមាន បទបញ្ញត្តិរដ្ឋបាលនិង/ ឬបទបញ្ញត្តិច្បាប់ ឱ្យបានត្រឹមត្រូវ ដើម្បីផ្តល់លទ្ធភាពឱ្យជនរងគ្រោះជាសាក្សីដែលបានយល់ព្រមសហការ បានបន្តស្នាក់នៅក្នុងប្រទេស ក្នុងគោលបំណង ជួយដល់ការស៊ើបអង្កេត និង/ឬ ផ្តល់ភស្តុតាង នៅក្នុងនីតិវិធីរឿងក្តីព្រហ្មទណ្ឌ ។

៥-ព្រះរាជអាជ្ញាជំនាញនិងបណ្តាទីភ្នាក់ងារគាំទ្រជនរងគ្រោះត្រូវរួមសហប្រតិបត្តិការគ្នា ដើម្បីគាំទ្រដល់ជនរងគ្រោះឱ្យបានចប់ចុងចប់ដើម ក្នុងពេលពួកគេចូលរួមនៅក្នុងនីតិវិធីរឿងក្តីព្រហ្មទណ្ឌ ។

៦-ត្រូវគោរពដល់ជីវិតឯកជន របស់ជនរងគ្រោះដោយសារអំពើជួញដូរ និងត្រូវរក្សាការសំងាត់នូវលក្ខណៈពិសេសផ្ទាល់ខ្លួនរបស់គេ ទៅតាមកំរិតដែលច្បាប់បានចែង ។

៧-តាមលទ្ធភាពដែលអាចធ្វើទៅបាន ត្រូវធ្វើការខិតខំ ដើម្បីពន្លឿនចំណាត់ការរឿងក្តីព្រហ្មទណ្ឌ នៅក្នុងករណីរឿងក្តីជួញដូរមនុស្ស ដើម្បីកាត់បន្ថយ នូវភាពតានតឹង និង សម្ពាធដែលជនរងគ្រោះកំពុងតែទទួលរងក្នុងខណៈពួកគេ ត្រូវទន្ទឹងរង់ចាំរយៈពេលយូរ ដើម្បីផ្តល់ភស្តុតាង នៅឯសវនាការជំនុំជំរះ ។

## ឃ -បណ្តាវិធានការពិសេស សំរាប់កុមាររងគ្រោះ

១-គ្រប់បណ្តាស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌ ត្រូវទទួលស្គាល់ និងគោរពនូវសេចក្តីត្រូវការពិសេស របស់កុមារជាជនរងគ្រោះដោយសារអំពើជួញដូរ ក៏ដូចជា សិទ្ធិពិសេសដែលត្រូវទទួលបាន នូវកិច្ចការពារ ការថែទាំ និងការគាំទ្រ ។

## ង -បញ្ហានៃកិច្ចការពារសាក្សី

១-ជនរងគ្រោះជាសាក្សី ព្រមទាំងក្រុមគ្រួសាររបស់ពួកគេប្រសិនបើចាំបាច់ ត្រូវទទួលបានកិច្ចការពារពីការសងសឹក ពីសំណាក់ពួកជួញដូរ ។

២-ត្រូវការពាររឿងអាថ៌កំបាំងផ្ទាល់ខ្លួន របស់ជនរងគ្រោះគ្រប់ពេលវេលា ទៅតាមកំរិតដែលច្បាប់បានចែង ។

៣-តាមលទ្ធភាពដែលច្បាប់ក្នុងស្រុកអនុញ្ញាតិឱ្យ ត្រូវធ្វើការពិចារណាដល់ការបំលាស់ទី របស់ជនរងគ្រោះជាសាក្សី ដែលបានព្រមព្រៀង ដោយរួមទាំង ការតាំងទីលំនៅ នៅប្រទេសទីពីរ ឬទីបីផង ប្រសិនបើ ការផ្លាស់ប្តូរទីលំនៅនេះជាការចាំបាច់ ដើម្បីការពារពួកគេ ។

## ច -បញ្ហាជំនុំជំរះ

១-ព្រះរាជអាជ្ញា និង អ្នកស៊ើបអង្កេតត្រូវធ្វើការឱ្យបានជិតស្និតជាមួយគ្នា ដើម្បីធានា ឱ្យទទួលបាន ការយល់ព្រម និងការសហការពីជនរងគ្រោះដោយសារអំពើជួញដូរដើម្បីផ្តល់នូវភស្តុតាង នៅក្នុងការកាត់ទោសពួកជួញដូរនៅក្នុងករណីរឿងទាំងឡាយដែលក្នុងនោះ ការផ្តល់ភស្តុតាងរបស់ពួកគេ គឺជាការចាំបាច់សំរាប់ការផ្តន្ទាទោស ។

២-ដើម្បីបំរើឱ្យផលប្រយោជន៍យុត្តិធម៌ និង ដើម្បីការពារជនរងគ្រោះ នោះការជំនុំជំរះដែលទាក់ទងនឹង អំពើជួញដូរមនុស្សត្រូវចាប់ផ្តើម និង បញ្ចប់ទៅដោយគ្មានការពន្យាពេល ដែលមិនសមហេតុផលឡើយ ។ ប្រសិនបើអាចធ្វើទៅបាន ត្រូវធ្វើការពិចារណាដល់បណ្តាយន្តការ ដូចជា ការបើកសវនាការជាបឋម ។

៣-ដើម្បីកាត់បន្ថយភាពតានតឹង នៅឯសវនាការជំនុំជំរះសំរាប់ជនរងគ្រោះជាសាក្សី ដែលកំពុងផ្តល់ភស្តុតាង ត្រូវរិះរកបណ្តាជំរើសផ្សេងៗ ដើម្បីផ្តល់ភស្តុតាងជាចំហនៅតុលាការ ជំរើសទាំងនោះ អាចរួមបញ្ចូល ការផ្តល់ភស្តុតាង ពីខាងក្រោយផ្ទាំងសំពត់ (អេក្រង់) ឬ នៅដំណាក់កាលជំនុំជំរះក្តីជាសំងាត់ ឬដោយមធ្យោបាយនៃ ការតភ្ជាប់បណ្តាញវីដេអូ ។

៤-បណ្តាវិធានការគាំទ្រជាក់ស្តែងផ្សេងទៀត ដល់តុលាការរួមមានៈ ការពិនិត្យមើលបន្ទប់តុលាការ មុនពេលការជំនុំជំរះការជូនទៅកាន់អាគារតុលាការ និងជូនត្រលប់មកវិញ ការប្រើប្រាស់ច្រកចូលទៅកាន់អាគារតុលាការផ្សេងគ្នា កន្លែងរង់ចាំដោយឡែកពីគ្នា និង ការផ្តល់ពត៌មានយ៉ាងទៀងទាត់ពី ផ្នែកអយ្យការ ស្តីពីការប្រព្រឹត្តទៅនៃការជំនុំជំរះ រហូតដល់ទីបញ្ចប់របស់នីតិវិធីរឿងក្តីនៅតុលាការ ។

៥-ទាំងព្រះរាជអាជ្ញា និង ចៅក្រមត្រូវទទួលខុសត្រូវ ក្នុងការធានាថា ការជំនុំជំរះប្រព្រឹត្តទៅដោយយុត្តិធម៌ អនុលោមទៅតាមបទដ្ឋានអន្តរជាតិ ដែលអាចអនុវត្តបាន ។

# ផ្នែកទីពីរៈ កិច្ចសហប្រតិបត្តិការអន្តរជាតិ លើផ្នែកប្រតិបត្តិការ និង ច្បាប់ឬតុលាការ

## ក -កិច្ចសហប្រតិបត្តិការអន្តរជាតិលើផ្នែកប្រតិបត្តិការ

១-ត្រូវធ្វើកិច្ចប្រឹងប្រែង ដើម្បីបង្កើត ការដាក់ពង្រាយក្រុមសំរបសំរួលស៊ើបអង្កេតនៃអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញាជំនាញនៅថ្នាក់អន្តរជាតិ ។

២-ត្រូវបង្កើតកិច្ចសហការក្នុងការប្រើប្រាស់បច្ចេកទេសស៊ើបអង្កេតជំនាញ នៅក្នុងការស៊ើបអង្កេតជាលក្ខណៈអន្តរជាតិ ។

៣-ត្រូវបង្កើតឱ្យមាន សិក្ខាសាលាបណ្តុះបណ្តាលថ្នាក់តំបន់ស្តីពីការគ្រប់គ្រងសំរបសំរួល ក្រុមស៊ើបអង្កេត និងការអនុវត្តន៏បច្ចេកទេសស៊ើបអង្កេតជំនាញ ។

៤-ត្រូវបង្កើត អង្គភាពទំនាក់ទំនងព្រំដែន បែបពហុទីភ្នាក់ងារជាតិ ជាពិសេសនៅត្រង់កន្លែងដែលត្រូវបានកំណត់ថាជា "ចំណុចក្តៅ " ដើម្បីកែលំអរសមត្ថភាព និងគុណភាពកិច្ចសហប្រតិបត្តិការឆ្លងដែន ។

៥-បណ្តាស្ថាប័នពាក់ព័ន្ធ ត្រូវបានលើកទឹកចិត្ត និង ទទួលការគាំទ្រ ក្នុងការប្រើប្រាស់ ប្រកបដោយប្រសិទ្ធភាពនូវបច្ចេកទេស និងការផ្លាស់ប្តូរពត៌មានបែបទំនើបនៅគ្រប់ជាន់ថ្នាក់ ដើម្បីសំរបសំរួលឱ្យកិច្ចសហប្រតិបត្តិការគ្នាកាន់តែជិតស្និទ្ធ និងឆាប់រហ័ស ។

៦-ត្រូវសម្របសម្រួល ឱ្យបានជិតស្និទ្ធ នូវបណ្តាវិធានការសហប្រតិបត្តិការអន្តរជាតិ លើផ្នែកប្រតិបត្តិការជាមួយនឹងបណ្តារចនាសម្ព័ន្ធតំបន់សមស្របផ្សេងទៀត ដូចជាដំណើរការប្រធានអង្គភាពជំនាញប្រឆាំងនឹងអំពើជួញដូរ ប៉ូលីសអន្តរជាតិ និងកិច្ចប្រជុំរួម របស់បណ្តាទីភ្នាក់ងារអនុវត្តច្បាប់អាស៊ាន ។

## ខ -កិច្ចសហប្រតិបត្តិការអន្តរជាតិជាទូទៅ លើផ្នែកច្បាប់ ឬ តុលាការ

១-ការប្រើប្រាស់គោលការណ៍ " ធ្វើបត្យាប័ន ឬ ផ្តន្ទាទោស " ត្រូវបានលើកទឹកចិត្ត ដើម្បីធ្វើជាមគ្គុទេសន៏សំរាប់គ្រប់សកម្មភាពដែលទាក់ទងនឹង ការផ្តន្ទាទោសករណីជួញដូរមនុស្សឆ្លងដែន ។

២-បើអាចធ្វើទៅបាន ត្រូវភ្ជាប់បទបញ្ញត្តិដែល អនុវត្តក្រៅដែនដី ទៅនឹងច្បាប់ជួញដូរមនុស្ស និង ច្បាប់ដែលទាក់ទងដើម្បីធ្វើជាវិធានការបន្ថែម សំដៅលុបបំបាត់ទីជំរកសុវត្ថិភាពរបស់ពួកជួញដូរមនុស្ស ។

៣-បណ្តារដ្ឋជាសមាជិកអាស៊ានត្រូវពិនិត្យមើលឡើងវិញនិងធ្វើឱ្យច្បាប់ក្នុងស្រុក ស៊ីសង្វាក់គ្នា ទៅតាមក៏រិត ដែលអាចធ្វើទៅបាន ដើម្បីធានាថាបត្យាប័ននិងការផ្តល់ជំនួយផ្នែកច្បាប់ទៅវិញទៅមក អាចដំណើរការទៅបាន ប្រកបដោយប្រសិទ្ធភាព ។

## គ -កិច្ចសហប្រតិបត្តិការអន្តរជាតិជាទូទៅ លើផ្នែកច្បាប់ ឬ តុលាការ -បត្យាប័ន

១-ការបញ្ជាប់ និង ការអនុវត្តន៏ ប្រកបដោយប្រសិទ្ធភាព នូវសន្ធិសញ្ញាបត្យាប័នទ្វេភាគី និង កិច្ចខិតខំព្យាយាម ដើម្បីឱ្យបានសំរេច នូវសន្ធិសញ្ញាបត្យាប័នអាស៊ានគំរូ នឹងជាការបោះជំហ៊ានឆ្ពោះទៅមុខដ៏សំខាន់ ក្នុងការបញ្ចប់និទណ្ឌភាព របស់ពួកជួញដូរមនុស្ស ។

២-នៅពេលដែលមិនអាចធ្វើបត្យាប័នបាន ដោយសារតែគ្មានសន្ធិសញ្ញា នោះមធ្យោបាយផ្សេងទៀត ដូចជា ការប្រើប្រាស់អនុសញ្ញាសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ដែលមានការចាត់តាំង នេះប្រសិនបើអាចអនុវត្តបាន ឬក៏ត្រូវពិចារណាដល់ ការរៀបចំនានានៅថ្នាក់អន្តរជាតិ ថ្នាក់តំបន់ និងទ្វេភាគីនិងដោយឈរលើមូលដ្ឋាន មួយករណីម្តងៗ ។

៣-នៅក្នុងករណីរឿងក្តីឆ្លងដែនដែលមានលក្ខណៈសមស្របនោះពួកជួញដូរអាចត្រូវទទួលការកាត់ទោសនៅក្នុងរដ្ឋពីរឬលើសពីនេះ នោះមធ្យោបាយដែលជាជំរើសផ្សេងនៅថ្នាក់អន្តរជាតិ ថ្នាក់តំបន់ ឬ ទ្វេភាគីអាចត្រូវយកមកពិចារណា ដើម្បីវាយតំលៃ និង សំរបសំរួល នីតិវិធីព្រហ្មទណ្ឌ ហើយប្រសិនបើមានលក្ខណៈសមស្របនោះ ត្រូវមានការពិចារណាដល់ការផ្ទេរនីតិវិធីរឿងក្តីព្រហ្មទណ្ឌទៅឱ្យរដ្ឋដែលសមស្របបំផុត ដើម្បីជាផលប្រយោជន៏ដល់ការផ្តល់ យុត្តិធម៌ត្រឹមត្រូវ ។

៤-ប្រសិនបើមានលក្ខណៈសមស្រប ត្រូវធ្វើការពិចារណាដល់ការបង្កើតបទបញ្ញត្តិច្បាប់ជាក់លាក់ ដើម្បីជួយសំរួលដល់ការផ្ទេរនីតិវិធីព្រហ្មទណ្ឌក្នុងករណីរឿងឆ្លងដែន នៅក្នុងតំបន់អាស៊ាន ។

## ឃ -កិច្ចសហប្រតិបត្តិការអន្តរជាតិជាទូទៅលើផ្នែកច្បាប់ ឬ តុលាការ -ជំនួយផ្នែកច្បាប់ទៅវិញទៅមក នៅក្នុងរឿងក្តីព្រហ្មទណ្ឌ

១-សន្ធិសញ្ញាស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមក នៅក្នុងរឿងព្រហ្មទណ្ឌ ក្នុងចំណោមប្រទេសដែលជាសមាជិកអាស៊ាន ដែលមានគំនិតដូចគ្នា គឺជាការបោះជំហានឆ្ពោះទៅមុខដ៏សំខាន់ ក្នុងការបញ្ចប់និទណ្ឌភាពរបស់ពួកជួញដូរ ហើយរដ្ឋជាសមាជិកអាស៊ានទាំងអស់ ត្រូវផ្តល់សច្ចាប័ន ឱ្យបានកាន់តែឆាប់កាន់តែប្រសើរ ។

២-អ្នកអនុវត្តផ្ទាល់ទាំងអស់ ត្រូវបានលើកទឹកចិត្ត ឱ្យទទួលយក និង ប្រើប្រាស់គំរូបែបបទនៃសន្ធិសញ្ញាស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមក ដូចមាន ចុះផ្សាយនៅលើគេហទំព័រ របស់លេខាធិការដ្ឋាននៃសន្ធិសញ្ញានិងត្រូវមានការទំនាក់ទំនងគ្នាឱ្យបានកាន់តែជិតស្និទ្ធ និងរហ័សថែមទៀត រវាងអាជ្ញាធរកណ្តាល និង ព្រះរាជអាជ្ញា នៅក្នុងករណីរឿងជួញដូរ ដែលពាក់ព័ន្ធដល់ការស្នើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមក ។

៣-បើអាចធ្វើទៅបាន រដ្ឋនានាត្រូវបានលើកទឹកចិត្ត ដើម្បីផ្តល់លទ្ធភាពឱ្យប្រើប្រាស់ និងទទួលយកភស្តុតាងជារូបភាពតាមរយៈការតបណ្តាញទូរទស្សន៏ នៅក្នុងតុលាការ ហើយដើម្បីឱ្យតុលាការមានលទ្ធភាពធ្វើដូច្នេះ ត្រូវបំពាក់ឧបករណ៍ និង ធនធានឱ្យបានពេញលេញ សំរាប់ការប្រើប្រាស់ ភស្តុតាងជារូបភាពវីដេអូ ។

៤- ការស្នើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមក ត្រូវអនុលោមទៅតាម  នីតិវិធីដែលបានកំណត់ស្រាប់ នៅក្នុងសន្ធិសញ្ញាជំនួយផ្នែកច្បាប់ទៅវិញទៅមក នៅក្នុងរឿងព្រហ្មទណ្ឌ នៅក្នុងចំណោមប្រទេសជាសមាជិកអាស៊ានដែលមានគំនិតដូចគ្នា ។ រដ្ឋនានា ត្រូវឱ្យអាទិភាពខ្ពស់  ដល់ការស្នើសុំ និង ពន្លឿនការស្នើសុំ ដែលទាក់ទងនឹងករណីរឿងជួញដូរទាំងនោះ ។

៥-រដ្ឋទទួលសំណើត្រូវទទួលស្គាល់ភ្លាមថា ខ្លួនបានទទួលសំណើតាមសន្ធិសញ្ញាស្តីពីជំនួយផ្នែកច្បាប់ទៅវិញទៅមក ដែលទាក់ទងដល់អំពើជួញដូរមនុស្ស  ហើយ ផ្តល់ជូនរដ្ឋជាម្ចាស់សំណើ នូវពតិមានបច្ចុប្បន្នភាពទៀងទាត់ ស្តីពីវឌ្ឍនភាពរបស់សំណើវិញ ។

៦-ត្រូវធ្វើការពិចារណាដល់ការធ្វើវិសោធនកម្មច្បាប់ក្នុងស្រុក ដើម្បីធានាដល់ការចាត់វិធានការក្នុងការកំណត់អត្តសញ្ញាណ តាមដាន និងបង្កកទុកឬដកហូត ចំណូលដែលបានមកពីបទល្មើសជួញដូរមនុស្ស សំរាប់គោលបំណង នៃការរឹបអូស ជាយថាហេតុ ។

៧-ត្រូវធ្វើការពិចារណាផងដែរ  ដល់ការធ្វើបញ្ចប់សន្ធិសញ្ញាកិច្ចព្រមព្រៀង  ឬ ការរៀបចំនានា  ជាទ្វេភាគី ដើម្បីលើកកំពស់ប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការអន្តរជាតិ លើផ្នែកច្បាប់ ឬ តុលាការស្តីពីករណីរឿងក្តីជួញដូរមនុស្ស ។

៨-សមាជិកតុលាការ ព្រះរាជអាជ្ញា និង អ្នកស៊ើបអង្កេតជំនាញ ត្រូវទទួលបានការបណ្តុះបណ្តាល និង ការគាំទ្រស្តីពីវិធានការកិច្ចសហប្រតិបត្តិការអន្តរជាតិ លើផ្នែកច្បាប់ ឬ តុលាការដោយសង្កត់ធ្ងន់ ជាពិសេសទៅលើ ការប្រើប្រាស់ និង ការទទួលយកនៅក្នុងតុលាការនូវភស្តុតាង ដែលទទួលបានមកតាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិខាងផ្នែកច្បាប់ ។

៩-ធ្វើការស្រាវជ្រាវទៅ ក្នុងការអនុវត្តន៍បណ្តាវិធានការនៃកិច្ចសហប្រតិបត្តិការអន្តរជាតិលើផ្នែកច្បាប់ ឬ តុលាការ និង ការប្រឆាំងនឹងការសំអាតប្រាក់ដែលទាក់ទងនឹង ករណីរឿងក្តីជួញដូរមនុស្ស ត្រូវអនុវត្តនៅក្នុងតំបន់អាស៊ានហើយលទ្ធផលដែលទទួលបាន ត្រូវយកទៅផ្សព្វផ្សាយ ឱ្យបានទូលំទូលាយ ។

## ង -បណ្តាញ

១-កិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ  ក្នុងផ្នែកប្រតិបត្តិការរវាង អ្នកស៊ើបអង្កេត និង ព្រះរាជអាជ្ញាជំនាញ គឺជាសមាសភាគដ៏ចាំបាច់សំរាប់ការឆ្លើយតបចំពោះអំពើជួញដូរមនុស្សប្រកបដោយប្រសិទ្ធភាព ព្រមទាំងត្រូវបង្កើតឡើង  នូវបណ្តាញព្រះរាជអាជ្ញាជំនាញនៅថ្នាក់តំបន់ ប្រហាក់ប្រហែលគ្នានឹង ដំណើរការប្រធានអង្គភាពជំនាញប្រឆាំងនឹងអំពើជួញដូរ ។

២-បណ្តាញព្រះរាជអាជ្ញាជំនាញថ្នាក់តំបន់ ត្រូវបង្កើតទំនាក់ទំនង លើផ្នែកប្រតិបត្តិការ ឱ្យបានជិតស្និទ្ធបំផុតជាមួយដំណើរការប្រធានអង្គភាពជំនាញប្រឆាំងនឹងអំពើជួញដូរ ដើម្បីធានាការសហការគ្នាឱ្យបានជិតស្និទ្ធ ។

៣-ត្រូវបង្កើតកម្មវិធីថ្នាក់តំបន់ ដើម្បីលើកស្ទួយកិច្ចសហប្រតិបត្តិការ និង បណ្តាញឱ្យបានជិតស្និទ្ធរវាងអ្នកស៊ើបអង្កេត ព្រះរាជអាជ្ញាជំនាញ និងមន្ត្រីច្បាប់នៅអាជ្ញាធរកណ្តាលនិងរួមទាំងបណ្តាសកម្មភាពនានា ដូចជាសិក្ខាសាលាបណ្តុះបណ្តាល   សិក្ខាសាលានានា និងការចូលរួមក្នុងចំណោមមហាជន ។

៤-ត្រូវបង្កើតគេហទំព័រជាក់លាក់មួយ ដើម្បីសំរបសំរួលបណ្តាញថ្នាក់តំបន់ សំដៅផ្តល់លទ្ធភាពដល់អ្នកជំនាញឯកទេស  ធ្វើការប្រាស្រ័យទាក់ទងគ្នា ក្រៅផ្លូវការ ដើម្បីចែករំលែកបទពិសោធន៍នៃការអនុវត្តន៍ល្អបំផុត និង ដើម្បីធ្វើជាសៀវភៅទំនាក់ទំនងជំនាញថ្នាក់តំបន់ សំរាប់ជនបង្គោលដែលបានតែងតាំង ។

## ការឆ្លើយតបផ្នែកយុត្តិធម៌ព្រហ្មទណ្ឌ  ចំពោះអំពើជួញដូរមនុស្ស៖
## គោលការណ៍ណែនាំអាស៊ានសំរាប់អ្នកអនុវត្តផ្ទាល់

[ដូចដែលបានបញ្ជាប់ជាស្តាពរដោយ  ក្រុមការងារពិសេសអាស៊ាន ស្តីពីការជួញដូរមនុស្ស នៅថ្ងៃទី ២៥ មិថុនា ២០០៧  នៅទីក្រុងវៀងច័ន្ទ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ  និងត្រូវបានអនុម័តដោយកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន នៅទីក្រុងវៀងច័ន្ទ នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ  នៅថ្ងៃទី ២៧ មិថុនា ២០០៧]

គោលបំណងជាទូទៅនៃគោលការណ៍ណែនាំសំរាប់អ្នកអនុវត្តផ្ទាល់នេះ  គឺដើម្បីជួយដល់បណ្តាស្ថាប័នយុត្តិធម៌ព្រហ្មទណ្ឌ  របស់បណ្តាប្រទេសជាសមាជិកអាស៊ាន  ដែលមានបំណង  ក្នុងការធានាយុត្តិធម៌  សំរាប់ជនរងគ្រោះ  និងបញ្ចប់និទណ្ឌភាព  របស់ពួកជួញដូរមនុស្ស។